**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ១៦ . អនក្រ.បក**

# អនុក្រឹត្យ
# ស្តីពី
# ការទទួលស្គាល់សាកលវិទ្យាល័យអន្តរជាតិឡូវី

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា ១.-**

ទទួលស្គាល់ការបង្កើតគ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា សាកលវិទ្យាល័យអន្តរជាតិឌូវី (Dewey International University ) សរសេរកាត់ជាភាសាខ្មែរ ស.អ.ឌ និងសរសេរកាត់ជាភាសាអង់គ្លេស D.I.U។

**មាត្រា ២.-**

សាកលវិទ្យាល័យអន្តរជាតិឌូវី មានទីតាំងស្ថិតនៅភូមិរំចេក៤ សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង និងស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៣.-**

សាកលវិទ្យាល័យអន្តរជាតិឌូវី ធ្វើការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្ររង និងបរិញ្ញាបត្រលើមហាវិទ្យាល័យប្រាំ ៖

១- មហាវិទ្យាល័យសិល្បៈ មនុស្សសាស្ត្រ និងភាសា
២- មហាវិទ្យាល័យគណិតសាស្ត្រ និងវិទ្យាសាស្ត្រ
៣- មហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម
៤- មហាវិទ្យាល័យអប់រំ
៥- មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម

សាកលវិទ្យាល័យអន្តរជាតិឌូវី ត្រូវរៀបចំកម្មវិធីសិក្សាលម្អិត តាមកម្រិត និងមុខជំនាញ ដើម្បីសុំការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា មុននឹងចាប់ផ្តើមដំណើរការបណ្តុះបណ្តាល។ ទៅអនាគត សាកលវិទ្យាល័យនេះអាចបើកសាខា មហាវិទ្យាល័យថ្មី មុខជំនាញថ្មី កម្រិតឬថ្នាក់ថ្មី ប្រភេទបណ្តុះបណ្តាលថ្មី ប្តូរឈ្មោះ ឬទីតាំងថ្មី ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៤.-**

សាកលវិទ្យាល័យអន្តរជាតិឌូវី ត្រូវមានក្រុមប្រឹក្សាភិបាលមួយ ដើម្បីពិនិត្យ និងសម្រេចលើគោលនយោបាយ ផែនការអភិវឌ្ឍ កម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត។ ការរៀបចំក្រុមប្រឹក្សាភិបាល ត្រូវមានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា ៥.-**

សាកលវិទ្យាធិការ សាកលវិទ្យាល័យអន្តរជាតិ ឌូវី មានភារកិច្ច ៖

-ទទួលខុសត្រូវចំពោះមុខច្បាប់ ក្នុងការគ្រប់គ្រងសាកលវិទ្យាល័យអន្តរជាតិឌូវី និងធានាឲ្យមានសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម។
-ទទួលខុសត្រូវក្នុងការជ្រើសរើសនិស្សិតឲ្យចូលរៀន និងទទួលនិស្សិតឲ្យសិក្សាបន្តតាមកម្មវិធីសិក្សា របស់សាកលវិទ្យាល័យអន្តរជាតិឌូវី។
-អនុវត្តតាមបទដ្ឋាន របស់ក្រសួងអប់រំ យុវជន និងកីឡា ដែលកំណត់លើសកម្មភាពនៃការធានាគុណភាពអប់រំ។
-រៀបចំតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធគ្រប់គ្រងសាកលវិទ្យាល័យ និងវិធានផ្ទៃក្នុងសម្រាប់

ការគ្រប់គ្រងការសិក្សា ឲ្យបានច្បាស់លាស់។

-ធ្វើរបាយការណ៍ប្រចាំឆ្នាំ មកនាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា តាមការកំណត់។

**មាត្រា ៦.-**

និស្សិតសាកលវិទ្យាល័យអន្តរជាតិខ្វារី ដែលបានរៀនចប់កម្មវិធីសិក្សា និងទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិត និងមុខជំនាញដែលបានសិក្សា។ សញ្ញាបត្រនេះ ផ្តល់ឱ្យដោយសាកលវិទ្យាល័យអន្តរជាតិខ្វារី ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីនិស្សិតសាកលវិទ្យាល័យអន្តរជាតិខ្វារី បំពេញ និងអនុវត្តបានតាមគោលការណ៍ និងបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងក្រុមប្រឹក្សាភិបាល រួមជាមួយសាកលវិទ្យាធិការនៃសាកលវិទ្យាល័យអន្តរជាតិខ្វារី ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ មករា ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលាខេត្តបាត់ដំបង
- ដូចមាត្រា ៧
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ